# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ......៥៣......អនក្រ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការពិនិត្យវាយតំលៃការិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១:** បង្កើត **គណៈកម្មាធិការពិនិត្យវាយតំលៃការិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា** ដែលមានសមាសភាពដូចខាងក្រោម÷

១- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា **ប្រធាន**

២-ឯកឧត្តម បណ្ឌិតរដ្ឋ **ពិច សំណាង** អគ្គលេខាធិការ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា **អនុប្រធានអចិន្ត្រៃយ៍**

៣- ឯកឧត្តម **ម៉ក់ ថាវិន** អគ្គនាយក នៃអគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេស និង វិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា **សមាជិក**

៤- ឯកឧត្តម **រស់ ចន្ទ្រាបុត្រ** អនុប្រធានរាជបណ្ឌិតសភាកម្ពុជា **សមាជិក**

៥- ឯកឧត្តម **គីម វ័ឌ្ឍវិសិដ្ឋ** ទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី **សមាជិក**

៦- ឯកឧត្តម **ឡៅ ហ៊ឹម** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **សមាជិក**

៧- ឧត្តមសេនីយ៍ទោ **នាង អេង** អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និង ជានាយកនាយកដ្ឋានអប់រំ ក្រសួងការពារជាតិ **សមាជិក**

៨- លោកបណ្ឌិត **ជេត ជាលី** អគ្គលេខាធិការរង នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា **សមាជិក**

៩- លោក **ប៉ែន ស៊ីផុល** ប្រធាននាយកដ្ឋាន ស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា **សមាជិក**

១០- លោក **ស សាម៉ុធី** ប្រធាននាយកដ្ឋាននីតិកម្ម និង វិវាទមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ **សមាជិក**

១១- លោក **យក់ សុផាន់ណា** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល **សមាជិក**

១២- លោក **ចាន់ សារុទ្ធ** អនុប្រធាននាយកដ្ឋាន បុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ **សមាជិក**

១៣-លោកស្រី **ម៉ក់ ណាង** អនុប្រធាននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា **សមាជិក**

១៤- លោក **ហ៊ីង យ៉ាន** ព្រឹទ្ធបុរសពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រសួងធម្មការ និងកិច្ចការសាសនា **សមាជិក**

១៥- លោក **ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ** ព្រឹទ្ធបុរសរង មហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ **សមាជិក**

**ប្រការ២:** ប្រធាន អនុប្រធាន និង សមាជិកទាំងអស់របស់គណៈកម្មាធិការនេះ ត្រូវមានសញ្ញាប័ត្រយ៉ាងទាបបំផុតពីថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ឡើងទៅ។

**ប្រការ៣:** គណៈកម្មាធិការនេះមានភារកិច្ចៈ

- វាយតំលៃគីរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា ក្នុងនិងក្រៅប្រទេស តាមសំណើសុំវាយតំលៃពីបុគ្គល ឬ ពីបណ្តាស្ថាប័ននានាទូទាំងប្រទេស។

- កសាងលក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃកំរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សាក្នុងនិងក្រៅប្រទេស ។

**ប្រការ៤:** អនុប្រធាន សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។
ក្នុងករណីប្រធានជាប់បំពេញបេសកកម្មក្រៅប្រទេស ឬ សុំច្បាប់ឈប់សំរាកពីការងារ ដោយមានធុរៈផ្សេងៗ អនុប្រធានអចិន្ត្រៃយ៍ត្រូវបំពេញតួនាទីជាប្រធានស្តីទី ។
ក្នុងពេលប្រជុំវាយតំលៃកំរិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា បុគ្គល ឬ ស្ថាប័នជាភាគីស្នើអាចចាត់តាំងតំណាង ឬ អោយសាមីជនមកជួបបំភ្លឺ និង ផ្តល់ពត៌មានដែលចាំបាច់ជូនគណៈកម្មាធិការ ។

**ប្រការ៥:** គណៈកម្មាធិការត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើត្រារបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីសំរួលការងារ ។
សមាសភាព និងតួនាទីភារកិច្ច របស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវកំណត់ដោយគណៈកម្មាធិការ ។

**ប្រការ៦:** សេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល និង បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិ នៃសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និង សមាសភាព ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ